# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

J-MOI-KT0193

# លក្ខន្តិកៈ

# សម្ព័ន្ធភាពជាតិឃុំ សង្កាត់
# នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ

# សម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា

1A

library.ncdd.gov.kh
014729

# លក្ខន្តិកៈ

# សម្ព័ន្ធភាពជាតិឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា


## បុព្វកថា

## ជំពូក ១

| | |
|---|---|
| មាត្រា ១-៣ | បទប្បញ្ញត្តិទូទៅ |

## ជំពូក ២

## គោលបំណង និងទិសដៅ

| | |
|---|---|
| មាត្រា ៤ | គោលបំណង |
| មាត្រា ៥ | ទិសដៅ |

## ជំពូក ៣

## សម្ព័ន្ធភាពជាតិឃុំ សង្កាត់

## រចនាសម្ព័ន្ធ និងតួនាទីរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់

| | |
|---|---|
| មាត្រា ៦ | លក្ខន្តិកៈសម្ព័ន្ធភាពជាតិឃុំ សង្កាត់ |
| មាត្រា ៧ | ត្រា និងរូបសញ្ញា |
| មាត្រា ៨ | សមាសភាព |
| មាត្រា ៩ | រចនាសម្ព័ន្ធ |
| មាត្រា ១០-១៣ | មហាសន្និបាត |
| មាត្រា ១៤-១៨ | ក្រុមប្រឹក្សាជាតិ |
| មាត្រា ១៩-២៤ | គណៈកម្មាធិការប្រតិបត្តិជាតិ |
| មាត្រា ២៥-២៦ | អគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ |

## ជំពូក ៤

## សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង រចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង


មាត្រា ២៧ លក្ខន្តិកៈសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង

មាត្រា ២៨ ត្រា និងរូបសញ្ញា

មាត្រា ២៩ លក្ខន្តិកៈសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង


## ជំពូក ៥

## សមាជិកភាពរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់


មាត្រា ៣០ ការចូលជាសមាជិកភាព

មាត្រា ៣១ ការបញ្ឈប់ពីសមាជិកភាព

មាត្រា ៣២ ការចូលជាសមាជិកភាពថ្មីម្តងទៀត


## ជំពូក ៦

## ការងារហិរញ្ញវត្ថុ


មាត្រា ៣៣-៣៥ ប្រាក់ចំណូលរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់

មាត្រា ៣៦ ការធ្វើសវនកម្មសម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងរបាយការណ៍សវនកម្ម

មាត្រា ៣៧ ប្រាក់ឧបត្ថម្ភរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់

មាត្រា ៣៨ ទ្រព្យសម្បត្តិរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៅពេលរំសាយ

## ជំពូក ៧

មាត្រា ៣៩ អន្តរប្បញ្ញត្តិ

## ជំពូក ៨

មាត្រា ៤០-៤១ អវសានប្បញ្ញត្តិ

# សម្ព័ន្ធភាពជាតិឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា

## បុព្វកថា

**ដោយអនុលោមតាម** ស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងជំពូក៣ មាត្រា៤២ ស្តីពី សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុង ការបង្កើតសមាគម ។

**ដោយហេតុថា** ក្រុមប្រឹក្សាឃុំ សង្កាត់នៅកម្ពុជា មានការប្តេជ្ញាចិត្តលើកកម្ពស់គុណភាពនៃជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ តាមរយៈអភិបាលកិច្ចបែបវិមជ្ឈការ ។

**ដោយហេតុថា** ក្រុមប្រឹក្សាឃុំ សង្កាត់ មានការប្តេជ្ញាចិត្តធានាឱ្យមានការផ្តល់សម្ភារបរិក្ខារ និងសេវាដែលមាន ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព តាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបោះឆ្នោតជ្រើសរើសឡើង ជាលក្ខណៈប្រជាធិបតេយ្យ ។

**ដោយហេតុថា** ជាការចាំបាច់ក្នុងការទទួលស្គាល់ និងបង្កើតអង្គការរួមមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីជំរុញ និងកៀរគរក្រុមប្រឹក្សាឱ្យសម្រេចបាននូវការប្តេជ្ញាចិត្តរួមទាំងនេះ ។

**ដោយហេតុថា** ក្រុមប្រឹក្សាឃុំ សង្កាត់នៅកម្ពុជា បានបង្កើតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ។

**ដូច្នេះ** សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង រួមគ្នាបង្កើតសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា ។

# ជំពូក ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

លក្ខន្តិកៈនេះ បង្កើតឱ្យមានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា (សរសេរជាអក្សរកាត់ ស.ជ.ឃ.ស.ក) ហៅកាត់ថា **សម្ព័ន្ធភាពជាតិឃុំ សង្កាត់** (សរសេរជាអក្សរកាត់ ស.ជ.ឃ.ស) និងមានឈ្មោះជាភាសាអង់គ្លេសថា National League of Commune Sangkat ( NLOCS) ។

លក្ខន្តិកៈនេះ ត្រូវអនុវត្តការងារក្នុងរង្វង់ក្របខ័ណ្ឌនៃសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

**មាត្រា ២.-**

លក្ខន្តិកៈនេះ នឹងចូលជាធរមានបន្ទាប់ពីមានសេចក្តីសម្រេចរបស់មហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់ លើកទី១។ សេចក្តីសម្រេចនេះ ត្រូវអនុម័តដោយការបោះឆ្នោតដែលមានសម្លេងគាំទ្រយ៉ាងតិចពីរភាគបីនៃចំនួនប្រតិភូពេញសិទ្ធិចូលរួមនៅក្នុងមហាសន្និបាត និងបន្ទាប់ពីបានចុះបញ្ជីតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

លក្ខន្តិកៈនេះអាចធ្វើវិសោធនកម្មបាន តាមសេចក្តីសម្រេចរបស់មហាសន្និបាត។ សេចក្តីសម្រេចនេះត្រូវ អនុម័តដោយការបោះឆ្នោត ដែលមានការគាំទ្រយ៉ាងតិចពីរភាគបីនៃចំនួនប្រតិភូពេញសិទ្ធិចូលរួមនៅក្នុងមហាសន្និបាត ។

សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ដែលមានបំណងធ្វើវិសោធនកម្មលក្ខន្តិកៈនេះ ត្រូវ ដាក់សំណើជាលាយល័ក្ខណ៍អក្សរជូនសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ឱ្យបានយ៉ាងតិច ៦ខែ មុនថ្ងៃធ្វើមហាសន្និបាត ។

## ជំពូក ២
## គោលបំណង និងទិសដៅ

### គោលបំណង

**មាត្រា ៤.-**

គោលបំណងរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ គឺ :

- លើកកម្ពស់ឋានៈ និងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង
- សម្រេចបាននូវរដ្ឋបាលប្រជាធិបតេយ្យ និងតាមបែបវិមជ្ឈការ ដែលមានប្រសិទ្ធភាព មាននិរន្តរភាព មានតម្លាភាព មានគណនេយ្យភាព និងមានការពឹងផ្អែកលើខ្លួនឯង ។

### ទិសដៅ

**មាត្រា ៥.-**

ទិសដៅរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ គឺ ដើម្បី :

- ជួយឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ក្លាយទៅជាស្ថាប័នប្រជាធិបតេយ្យដែលមានការពឹងផ្អែកលើខ្លួនឯង និងមាននិរន្តរភាព ។
- ធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្លើយតបបានច្រើនចំពោះតម្រូវការពិសេសរបស់ជនក្រីក្រ ស្ត្រី កុមារ និងក្រុមងាយរងគ្រោះផ្សេងទៀត ។

- ផ្តល់ និងសម្របសម្រួលកម្មវិធីកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ដោយឯករាជ្យ និងដោយមានការសហការជាមួយស្ថាប័ន និងអាជ្ញាធរជាតិ អន្តរជាតិ នៅមូលដ្ឋាន ។
- ពុះពារដើម្បីផ្តល់ឱកាសដល់ស្ត្រី អាចចូលរួមយ៉ាងពេញលេញនៅក្នុងអភិបាលកិច្ចមូលដ្ឋាន ។
- ជំរុញកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីលើកកម្ពស់ និងសម្រេចបាននូវ ស្វ័យអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យឱ្យមានប្រសិទ្ធភាពខ្ពស់ ។
- ជំរុញវប្បធម៌សហការ រៀនសូត្រ និងចែករំលែកនៅក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់ ។
- តំណាង និងការពារផលប្រយោជន៍ កង្វល់ និងតម្រូវការរួមរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងការរៀបចំ គោលនយោបាយ និងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្រុង ។
- ទំនាក់ទំនង និងពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាល និងទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល គណបក្សនយោបាយ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងអាជ្ញាធរផ្សេងទៀតនៅថ្នាក់ជាតិ អន្តរជាតិ និង នៅមូលដ្ឋាន អំពីបញ្ហាទាក់ទងនឹងអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ។
- លើកកម្ពស់និងជំរុញតួនាទីរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និង សមាគម ក្រុមប្រឹក្សាឃុំ សង្កាត់នៅតាម ខេត្ត ក្រុង ដែលជាអង្គការតំណាង និងពិគ្រោះយោបល់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

- បង្កើតច្រកទំនាក់ទំនង និងសហប្រតិបត្តិការជាមួយសមាគមអាជ្ញាធរមូលដ្ឋាន និងស្ថាប័នដែលមាន ទស្សនៈដូចគ្នានៅបរទេសសម្រាប់ការរៀនសូត្រ ការចែករំលែកបទពិសោធន៍ និងការគាំទ្រ ។

## ជំពូក ៣
## រចនាសម្ព័ន្ធ និងតួនាទីរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់

### មាត្រា ៦.-

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ គឺជានីតិបុគ្គល ។

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មានអាសយដ្ឋាន និង ការិយាល័យអចិន្ត្រៃយ៍ស្ថិតនៅរាជធានីភ្នំពេញប្រទេសកម្ពុជា ។

អាសយដ្ឋាន និងការិយាល័យអចិន្ត្រៃយ៍នេះ អាចផ្លាស់ប្តូរបានតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

កិច្ចការរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវកំណត់ដោយលក្ខន្តិកៈនេះ និងដោយបទបញ្ជារបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។ បទបញ្ជាសម្រាប់អនុវត្តក្នុងផ្ទៃកនានារបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវតាក់តែងឡើងដោយផ្អែកតាមលក្ខន្តិកៈនេះ ។

## ត្រា និងរូបសញ្ញា

### មាត្រា ៧.-

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវមានត្រានិងរូបសញ្ញាផ្លូវការរបស់ខ្លួន ។ ត្រារបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មាន**រាងមូល** រង្វង់ពីរជាន់គឺ រង្វង់ខាងក្រៅមានវិជ្ជមាត្រ៤,១សង់ទីម៉ែត្រ និងរង្វង់ខាងក្នុងមានវិជ្ជមាត្រ៣,០សង់ទី

ម៉ែត្រ ។ ផ្នែកខាងលើនៃរង្វង់ត្រា មានចារិកអក្សរខ្មែរថា **ព្រះរាជាណាចក្រកម្ពុជា** និងនៅផ្នែកខាងក្រោមមានចារិកអក្សរខ្មែរថា **សម្ព័ន្ធភាពជាតិឃុំ សង្កាត់** ហើយខ័ណ្ឌដោយ**ផ្កាចាន់**។ នៅចំណុចកណ្ដាលនៃត្រាមាន**រូបផែនទី**ព្រះរាជាណាចក្រ កម្ពុជា និងអក្សរបំព្រួញ **ស.ជ.ឃ.ស**។

រូបសញ្ញារបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មាន**រូបផែនទី**ព្រះរាជាណាចក្រកម្ពុជា ។ ក្នុងផែនទីមាន**រូបទង់ជាតិ** នៃព្រះរាជាណាចក្រកម្ពុជា ព័ទ្ធជារង្វង់ដោយកួរស្រូវពណ៌មាសភ្ជាប់ដោយខ្សែបូ អមដោយក្បាច់ភ្ញីភ្លើង និងចារិក អក្សរថា

**ស.ជ.ឃ.ស** មានអក្សរជារង្វង់ស្នែងក្របី ផ្នែកខាងក្នុង កួរស្រូវសរសេរថា **សម្ព័ន្ធភាពជាតិឃុំ សង្កាត់** នៃព្រះរាជាណាចក្រកម្ពុជា និងស្ថិតនៅលើផ្ទៃពណ៌បៃតង។

## សមាសភាព

### មាត្រា ៨.-

សមាសភាពសម្ព័ន្ធភាពជាតិឃុំ សង្កាត់ រួមមានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងក្នុងប្រទេសកម្ពុជាជាសមាជិក ។ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវចាប់ផ្ដើមដោយមានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាម ខេត្ត ក្រុង យ៉ាងតិចចំនួនប្រាំបួនចូលរួមជាសមាជិក។

ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានបំណងក្លាយទៅជាសមាជិករបស់សម្ព័ន្ធភាព ជាតិឃុំ សង្កាត់ ត្រូវចូលជាសមាជិករបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាម ខេត្ត ក្រុង ជាមុនសិន។ សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង គឺជាសមាជិករបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ផ្អែកតាមលក្ខន្តិកៈនេះ។

## រចនាសម្ព័ន្ធ

**មាត្រា ៩.-**

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មានរចនាសម្ព័ន្ធដូចខាងក្រោម :

- មហាសន្និបាត
- ក្រុមប្រឹក្សាជាតិ
- គណៈកម្មាធិការប្រតិបត្តិជាតិ
- អគ្គលេខាធិការដ្ឋាន ។

## មហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់

**មាត្រា ១០.-**

មហាសន្និបាត មានសមាសភាពចូលរួម :

- ប្រធាន និងអនុប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ។
- ប្រតិភូមកពីក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាសមាជិករបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ។ ចំនួនប្រតិភូនឹងត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិ ។
- ប្រតិភូគឺជាបុគ្គលដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងជាតំណាងផ្លូវការរបស់សមាជិកសមាគមនៅតាមខេត្ត ក្រុង ។

ប្រតិភូគ្រប់រូបអាចបោះឆ្នោតមួយសម្លេងលើរាល់កិច្ចការដែល តម្រូវឱ្យមានសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត ។

ក្រៅពីមានសិទ្ធិបោះឆ្នោតក្នុងឋានៈជាប្រតិភូ សម្លេងរបស់ប្រធានមហាសន្និបាតមានឧត្តមានុភាពក្នុងករណីដែលមានសម្លេងឆ្នោតស្មើគ្នាលើកិច្ចការដែល

តម្រូវឱ្យមានសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត ។ នីតិវិធី និងការជ្រើសរើសប្រតិភូចូលរួម ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

**មាត្រា ១១.-**

មហាសន្និបាតត្រូវបោះឆ្នោតជ្រើសរើសប្រធានមួយរូប និងអនុប្រធានមួយចំនួន ពីក្នុងចំណោមប្រតិភូចូលរួមនៅក្នុងមហាសន្និបាត ។

ប្រធាន និងអនុប្រធានដែលបានជាប់ឆ្នោត គឺជាប្រធាន និងអនុប្រធានមហាសន្និបាត ។

ប្រធាន និងអនុប្រធានមហាសន្និបាត គឺជាប្រធាន និងជាអនុប្រធានក្រុមប្រឹក្សាជាតិ ។

ប្រធាន និងអនុប្រធានក្រុមប្រឹក្សាជាតិ គឺជាប្រធាន និងជាអនុប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ ។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ គឺជាអគ្គលេខាធិការមហាសន្និបាត ។

នីតិវិធី និងការជ្រើសរើសប្រធាន និងអនុប្រធានមហាសន្និបាត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិ ។

**មាត្រា ១២.-**

មហាសន្និបាតត្រូវធ្វើការប្រជុំក្នុងរយៈពេលប្រាំឆ្នាំម្តង នៅក្នុងប្រទេសកម្ពុជា ។ ការប្រជុំនេះ ត្រូវប្រារព្ធឡើង ក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អាណត្តិនីមួយៗ ។

ក្រៅពីមហាសន្និបាតក្នុងរយៈពេលប្រាំឆ្នាំម្តង សម្ព័ន្ធភាពជាតិឃុំ សង្កាត់ អាចធ្វើ

មហាសន្និបាតវិសាមញ្ញ នៅពេលណាមួយនៅក្នុងប្រទេសកម្ពុជា ដើម្បីពិចារណាការងារដែលជាផលប្រយោជន៍របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងដើម្បីពិនិត្យ និងដោះស្រាយបញ្ហានៅមុនមហាសន្និបាតនាពេលបន្ទាប់ ។ ប្រធានក្រុមប្រឹក្សាជាតិត្រូវកោះប្រជុំមហាសន្និបាតនៅរៀងរាល់ប្រាំ ឆ្នាំម្តង។

ប្រធានក្រុមប្រឹក្សាជាតិ ត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញ នៅពេលមានសំណើជាលាយល័ក្ខណ៍អក្សរ ដោយមានបញ្ជាក់ប្រធានបទ និងមូលហេតុពីសំណាក់ :

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាសមាជិករបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មិនតិចជាង ៣៣ ភាគរយ ឬ
- សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង មិនតិចជាង ៣៣ ភាគរយ ឬ
- សមាជិកក្រុមប្រឹក្សាជាតិ មិនតិចជាង ៥០ភាគរយ ឬ
- សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ មិនតិចជាង ៧៥ភាគរយ ។

## មាត្រា ១៣.~

មហាសន្និបាតមានភារកិច្ចកំណត់ និងអនុម័ត :

- បទបញ្ជា និងនីតិវិធីបំពេញការងាររបស់ខ្លួនផ្ទាល់
- ត្រា និងរូបសញ្ញាជាផ្លូវការរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់
- ល័ក្ខខ័ណ្ឌសម្រាប់សមាជិករបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់

នីតិវិធីបំពេញការងារ ការកោះប្រជុំ ការប្រព្រឹត្តទៅនៃអង្គប្រជុំ និងការធ្វើ

ប្រតិភូកម្មការទទួលខុសត្រូវ ដល់ផ្នែកនានាដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

- នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើស និងការបញ្ឈប់ប្រតិភូនៅក្នុងក្រុមប្រឹក្សាជាតិ គណៈកម្មាធិការប្រតិបត្តិជាតិ និងគណៈកម្មការផ្សេងទៀតរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។
- ការងារហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងសមាគម ក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ព្រមទាំងផ្នែកនានា របស់សមាគម ។
- របៀបតែងតាំង ល័ក្ខខ័ណ្ឌការងារ ការទទួលខុសត្រូវ និងនីតិវិធីបំពេញការងាររបស់បុគ្គលិក រួមទាំងអគ្គលេខាធិការ ។
- ចាត់ចែងកិច្ចការរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ អនុលោមតាមគោលបំណង និងទិសដៅរបស់សមាគម ក្រុមប្រឹក្សាឃុំ សង្កាត់នៅ តាមខេត្ត ក្រុង និងសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដូចមានចែងនៅ ក្នុងលក្ខន្តិកៈនេះ ។
- ការពិនិត្យមើលឡើងវិញ និងសម្រេចលើកិច្ចការដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិ ឬអគ្គលេខាធិការ ។
- ការធ្វើវិសោធនកម្មលើលក្ខន្តិកៈសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។
- បទបញ្ជាផ្ទៃក្នុង ដោយមានល័ក្ខខ័ណ្ឌដូចគ្នា សម្រាប់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ចូលជាសមាជិក របស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់

នៅតាមខេត្ត ក្រុង។

- ការងារផ្សេងទៀតដែលមានលក្ខណៈសមស្រប ឬជាការចាំបាច់ ដោយផ្អែកតាមលក្ខន្តិកៈសម្ព័ន្ធភាពជាតិ ឃុំ សង្កាត់។

## ក្រុមប្រឹក្សាជាតិ

### មាត្រា ១៤.-

ក្រុមប្រឹក្សាជាតិ មានសមាសភាព :

- សមាជិកដែលត្រូវបោះឆ្នោតជ្រើសរើសឡើងដោយ និងពីក្នុងចំណោមប្រតិភូចូលរួមនៅក្នុងមហាសន្និបាត និង
- សមាជិកជាប្រតិភូចំនួនបីរូបពីក្នុងចំណោមគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុងនីមួយៗ។

ចំនួនសមាជិកក្រុមប្រឹក្សាជាតិដែលត្រូវបោះឆ្នោតជ្រើសរើសឡើងដោយ និងពីក្នុងចំណោមប្រតិភូចូលរួម នៅក្នុងមហាសន្និបាតនីមួយៗ ត្រូវបែងចែករវាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

ចំនួនសមាជិកក្រុមប្រឹក្សាជាតិ ដែលត្រូវបោះឆ្នោតជ្រើសរើសពីសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងនីមួយៗ ត្រូវគណនាតាមរូបមន្តដូចខាងក្រោម :

$$\left( \frac{\text{ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាសមាជិកសមាគមនៅតាមខេត្តក្រុងសាមី} \times \textbf{ចំនួនក្រុមប្រឹក្សាជាតិ}}{\text{ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់សរុបដែលជាសមាជិកសម្ព័ន្ធភាពជាតិឃុំ សង្កាត់}} \right) - ៣$$

(លទ្ធផលនៃការគណនាត្រូវយកលេខជាចំនួនគត់)

ចំនួនសមាជិកក្រុមប្រឹក្សាជាតិ កំណត់ដោយមហាសន្និបាត។ ប្រធានមហាសន្និបាត គឺជាប្រធានរបស់ក្រុមប្រឹក្សាជាតិ ហើយអនុប្រធានរបស់មហាសន្និបាត គឺជាអនុប្រធានក្រុមប្រឹក្សាជាតិ ដោយស្វ័យប្រវត្តិ។

**មាត្រា ១៥.-**

សមាជិកក្រុមប្រឹក្សាជាតិ មានអាណត្តិប្រាំឆ្នាំ លើកលែងតែសមាជិកក្រុមប្រឹក្សានេះ ត្រូវបានបញ្ឈប់មុន អាណត្តិដោយសេចក្តីសម្រេចរបស់មហាសន្និបាត។ បុគ្គលជាសមាជិកក្រុមប្រឹក្សាជាតិដែលបាត់បង់តំណែង ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ត្រូវបាត់បង់លក្ខណសម្បត្តិជាសមាជិកក្រុមប្រឹក្សាជាតិភ្លាមដែរ។

**មាត្រា ១៦.-**

ក្រុមប្រឹក្សាជាតិ ត្រូវធ្វើការប្រជុំក្នុងរយៈពេលមួយឆ្នាំម្តង នៅក្នុងប្រទេសកម្ពុជា។

ក្រៅពីការប្រជុំមួយឆ្នាំម្តង ក្រុមប្រឹក្សាជាតិអាចធ្វើការប្រជុំវិសាមញ្ញ នៅពេលណាមួយនៅក្នុងប្រទេសកម្ពុជា ដើម្បីពិចារណាការងារដែលជាផលប្រយោជន៍របស់ក្រុមប្រឹក្សាជាតិ និងដើម្បីពិនិត្យ និងដោះស្រាយនៅមុនពេលប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិនាពេលបន្ទាប់។

ប្រធានក្រុមប្រឹក្សាជាតិ ត្រូវកោះប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិ។ ប្រធានក្រុមប្រឹក្សាជាតិត្រូវកោះ ប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាជាតិ នៅពេលមានសំណើជាលាយល័ក្ខណ៍អក្សរ ដោយមានបញ្ជាក់ប្រធានបទ និង មូលហេតុពីសំណាក់ :

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ដែលជាសមាជិករបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់មិនតិចជាង៣៣ ភាគរយ ឬ
- សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងមិនតិចជាង៣៣ភាគរយ ឬ
- សមាជិកក្រុមប្រឹក្សាជាតិមិនតិចជាង៥០ភាគរយ ឬ
- សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ មិនតិចជាង៧៥ភាគរយ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សាជាតិ មានភារកិច្ច :

- គ្រប់គ្រង និងដឹកនាំការងាររបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់នៅចន្លោះពេលមហាសន្និបាតដែលរៀបចំឡើងក្នុងរយៈពេល៥ឆ្នាំម្តង ដោយអនុលោមតាមគោលបំណង និងទិសដៅរបស់សមាគម ក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង និងសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដូចមានក្នុងលក្ខន្តិកៈនេះ ។
- រៀបចំ និងអនុម័តបទបញ្ជាដែលអាចតម្រូវឱ្យមាននៅចន្លោះពេលមហាសន្និបាត ។
- ផ្តួចផ្តើម និងសម្រេចលើកិច្ចការដែលស្របនឹងគោលបំណង និងទិសដៅទាំងនេះ ។
- សម្រេចលើកម្មវិធី និងថវិកាប្រចាំឆ្នាំសម្រាប់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។
- ពិនិត្យមើលជាប្រចាំលើកិច្ចការហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

- សម្រេចលើរបៀបតែងតាំង និងល័ក្ខខ័ណ្ឌការងារ និងការទទួលខុសត្រូវរបស់បុគ្គលិក រួមទាំងអគ្គលេខាធិការ ។
- រាយការណ៍អនុសាសន៍ សេចក្ដីសម្រេច និងសកម្មភាពរបស់ខ្លួនជាលាយល័ក្ខណ៍អក្សរ និងដាក់របាយការណ៍សវនកម្មប្រចាំឆ្នាំ ជូនមហាសន្និបាតនាពេលបន្ទាប់ ។

សមាជិកគ្រប់រូបរបស់ក្រុមប្រឹក្សាជាតិ អាចមានសិទ្ធិបោះឆ្នោតមួយសម្លេងលើកិច្ចការដែលតម្រូវឱ្យមាន សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជាតិ ។

**មាត្រា ១៨.-**

ប្រធានក្រុមប្រឹក្សាជាតិ មានភារកិច្ច :

- រៀបចំកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាជាតិ ។
- ធ្វើជាអធិបតីអង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សាជាតិ ។
- អនុវត្តភារកិច្ចផ្សេងៗ ដែលតម្រូវដោយលក្ខន្តិកៈនេះ ឬដោយបទបញ្ជា ។
- ប្រកាន់យកការទទួលខុសត្រូវផ្សេងទៀត ដែលតម្រូវដោយសេចក្ដីសម្រេចរបស់មហាសន្និបាត ឬក្រុម ប្រឹក្សាជាតិ ។

ក្រៅពីមានសិទ្ធិបោះឆ្នោតក្នុងឋានៈជាប្រតិភូ សម្លេងរបស់ប្រធានក្រុមប្រឹក្សាជាតិមានឧត្តមានុភាព ក្នុងករណីមានសម្លេងឆ្នោតស្មើគ្នាលើកិច្ចការដែល តម្រូវឱ្យមានសេចក្ដីសម្រេចពីក្រុមប្រឹក្សាជាតិ ។

អនុប្រធាន ត្រូវទទួលតំណែងជាប្រធានស្ដីទីតាមការប្រគល់សិទ្ធិរបស់ប្រធាន នៅពេលប្រធានអវត្តមាន ។

## គណៈកម្មាធិការប្រតិបត្តិជាតិ

### មាត្រា ១៩.-

គណៈកម្មាធិការប្រតិបត្តិជាតិ មានសមាជិកដែលត្រូវបោះឆ្នោតជ្រើសរើសដោយ និងពីក្នុងចំណោមប្រតិភូ នៅក្នុងក្រុមប្រឹក្សាជាតិ។ ចំនួនសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិដែលត្រូវបោះឆ្នោតជ្រើសរើសឡើងដោយ និង ពីក្នុងចំណោមប្រតិភូនៅក្នុងក្រុមប្រឹក្សាជាតិ ត្រូវបែងចែករវាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

ចំនួនសមាជិកជាប្រតិភូសម្រាប់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងនីមួយៗ ត្រូវគណនាតាមរូបមន្តដូចខាងក្រោម :

| | | |
|---|---|---|
| ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាសមាជិកសមាគមនៅខេត្ត ក្រុងសាមី / ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់សរុបដែលជាសមាជិកសម្ព័ន្ធភាពជាតិឃុំ សង្កាត់ | × | ចំនួនសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ |

(លទ្ធផលនៃការគណនាត្រូវយកលេខជាចំនួនគត់)

ចំនួនសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិកំណត់ដោយមហាសន្និបាត។

ប្រធានក្រុមប្រឹក្សាជាតិ គឺជាប្រធានគណៈកម្មាធិការប្រតិបត្តិជាតិហើយ អនុប្រធានរបស់ក្រុមប្រឹក្សាជាតិ គឺជាអនុប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ ដោយស្វ័យប្រវត្តិ។

### មាត្រា ២០.-

សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ មានអាណត្តិប្រាំឆ្នាំ លើកលែងតែ

សមាជិកគណៈកម្មាធិការទាំងនេះ ត្រូវបានបញ្ឈប់នៅមុនអាណត្តិដោយសេចក្តីសម្រេចមិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាជាតិទាំងមូល ។

បុគ្គលដែលជាសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិដែលបាត់បង់តំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ត្រូវបាត់បង់លក្ខណសម្បត្តិជាសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ ដោយស្វ័យប្រវត្តិ ។

**មាត្រា ២១.-**

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវធ្វើការប្រជុំក្នុងរយៈពេលមួយ ឆ្នាំពីរដង នៅក្នុងប្រទេសកម្ពុជា។ ក្រៅពីការប្រជុំមួយឆ្នាំពីរដង គណៈកម្មាធិការប្រតិបត្តិជាតិអាចប្រជុំវិសាមញ្ញនៅក្នុងប្រទេសកម្ពុជា ដើម្បីពិចារណាការងារដែលជាផលប្រយោជន៍របស់គណៈកម្មាធិការប្រតិបត្តិជាតិ និងដើម្បីពិនិត្យ និងដោះស្រាយការងារនៅមុនការប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិជាតិនាពេលបន្ទាប់ ។

ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវកោះប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ មួយឆ្នាំយ៉ាងតិចពីរដង ។

ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិជាតិ នៅពេលមានសំណើជាលាយល័ក្ខណអក្សរពីសមាជិកនៅនៅក្នុងគណៈកម្មាធិការប្រតិបត្តិជាតិ មិនតិចជាងមួយភាគបី ដោយមានបញ្ជាក់ប្រធានបទ និងមូលហេតុ ។

នៅពេលប្រធានអវត្តមាន អនុប្រធានត្រូវទទួលការងារជាប្រធានស្តីទីទៅតាមការប្រគល់សិទ្ធិពីប្រធាន ។

## មាត្រា ២២.-

គណៈកម្មាធិការប្រតិបត្តិជាតិ មានភារកិច្ច ៖

- គ្រប់គ្រង និងពិនិត្យមើលការងាររបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៅចន្លោះពេលប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិ ដោយអនុលោមតាមគោលបំណង និងទិសដៅរបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ នៅតាមខេត្ត ក្រុង និងសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដូចមានចែងនៅក្នុងលក្ខន្តិកៈនេះ ។
- អាចផ្តួចផ្តើម និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាជាតិ ចំពោះការងារដែលស្របនឹងគោលបំណង និងទិសដៅទាំងនេះ ។
- អាចសម្រេច និងអនុវត្តការងារដែលស្របនឹងគោលបំណង និងទិសដៅ និងស្ថិតនៅក្នុងសិទ្ធិអំណាចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ ។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាជាតិ អំពីថវិកាប្រចាំឆ្នាំសម្រាប់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។
- ត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។
- តែងតាំង និងបញ្ឈប់ការងាររបស់អគ្គលេខាធិការ ។
- រាយការណ៍អនុសាសន៍ សេចក្តីសម្រេច និងសកម្មភាពរបស់ខ្លួនជាលាយល័ក្ខណ៍អក្សរ និងដាក់របាយការណ៍សវនកម្មប្រចាំឆ្នាំ ជូនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ នាពេលបន្ទាប់ ។

## មាត្រា ២៣.-

ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ មានភារកិច្ច ៖

- រៀបចំកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការប្រតិបត្តិជាតិ ។

- ធ្វើជាអធិបតីអង្គប្រជុំទាំងអស់របស់គណៈកម្មាធិការប្រតិបត្តិជាតិ ។
- អនុវត្តភារកិច្ចផ្សេងៗដែលតម្រូវដោយលក្ខន្តិកៈនេះ ឬដោយបទបញ្ជា ។
- ប្រកាន់យកការទទួលខុសត្រូវផ្សេងទៀតដែលតម្រូវដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ ឬក្រុមប្រឹក្សាជាតិ ។

## មាត្រា ២៤.-

គណៈកម្មាធិការប្រតិបត្តិជាតិ អាចតែងតាំងគណៈកម្មការពីក្នុងចំណោមសមាជិករបស់ខ្លួន ឬពីក្នុងចំណោម បុគ្គលផ្សេងទៀត ដើម្បីផ្តល់យោបល់ និងជួយការងាររបស់គណៈកម្មាធិការប្រតិបត្តិជាតិ ។ គណៈកម្មាធិការប្រតិបត្តិជាតិត្រូវសម្រេចលើល័ក្ខខ័ណ្ឌការងារ និងអំណាចរបស់គណៈកម្មការនីមួយៗ

# អគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិឃុំ សង្កាត់

## មាត្រា ២៥.-

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មានអគ្គលេខាធិការដ្ឋានរបស់ខ្លួន ដើម្បីគ្រប់គ្រងការងារប្រចាំថ្ងៃរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងផ្នែកនានារបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងដើម្បីជួយរៀបចំចាត់ចែងមហាសន្និបាត ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិ ទៅតាមការចាំបាច់ ។

ប្រធានអគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិ គឺជាអគ្គលេខាធិការរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់។ អគ្គលេខាធិការ គឺជាប្រធានរដ្ឋបាលនិងហិរញ្ញវត្ថុ របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។ អគ្គលេខាធិការអាចចូលរួម និងមានមតិនៅក្នុងអង្គប្រជុំទាំងអស់ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោត

## មាត្រា ២៦.-

អគ្គលេខាធិការត្រូវមានលក្ខណសម្បត្តិ និងបទពិសោធន៍វិជ្ជាជីវៈសមស្របលើការងារអភិបាលកិច្ច និងការអភិវឌ្ឍនៅមូលដ្ឋាន ។ អគ្គលេខាធិការមិនអាចបម្រើការងារផ្សេងទៀត ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងអំឡុងពេលតែមួយបានឡើយ ។ អគ្គលេខាធិការមានភារកិច្ច :

- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់
- គ្រប់គ្រង និងត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់
- រៀបចំថវិកាប្រចាំឆ្នាំរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងដាក់ជូនសម្ព័ន្ធភាពជាតិឃុំ សង្កាត់
- ត្រួតពិនិត្យ និងគ្រប់គ្រងបុគ្គលិក និងនិយោជិកទាំងអស់របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់
- ផ្តល់យោបល់ និងរាយការណ៍ជូនមហាសន្និបាត ក្រុមប្រឹក្សាជាតិ គណៈកម្មាធិការប្រតិបត្តិជាតិ និងគណៈកម្មការផ្សេងទៀតរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ទៅតាមការចាំបាច់
- អនុវត្តភារកិច្ចផ្សេងៗដែលតម្រូវដោយលក្ខន្តិកៈ ឬបទបញ្ជារបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់
- ប្រកាន់យកការទទួលខុសត្រូវផ្សេងទៀត ដែលតម្រូវដោយល័ក្ខខ័ណ្ឌការងាររបស់អគ្គលេខាធិការ ។

# ជំពូក ៤
## លក្ខន្តិកៈរបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង

### មាត្រា ២៧.-

សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងដែលបានបង្កើតឡើងផ្អែកតាមលក្ខន្តិកៈនេះ ត្រូវក្លាយទៅជាសមាជិកអចិន្ត្រៃយ៍របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ដោយស្វ័យប្រវត្តិ ហើយត្រូវទទួលយក និងអនុវត្តតាមបទប្បញ្ញត្តិនៅក្នុងលក្ខន្តិកៈនេះ។ កិច្ចការរបស់សមាគមនៅតាមខេត្ត ក្រុងត្រូវកំណត់ដោយលក្ខន្តិកៈនេះ និងដោយបទបញ្ជា ។ បទបញ្ជារបស់សមាគមនៅថ្នាក់ខេត្ត ក្រុងត្រូវរៀបចំតាក់តែងឡើងដោយសាមីសមាគមផ្ទាល់ ហើយត្រូវអនុលោមតាមលក្ខន្តិកៈនេះ និងមិនអាចមានលក្ខណៈផ្ទុយទៅនឹងបទបញ្ជារបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានឡើយ។ ក្នុងករណីមានលក្ខណៈផ្ទុយ គឺបទបញ្ជារបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មានអនុភាពលើបទបញ្ជារបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

## ត្រា និងរូបសញ្ញា

### មាត្រា ២៨.-

សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ត្រូវមានត្រា និងរូបសញ្ញាជាផ្លូវការរបស់ខ្លួន។ ត្រា និងរូបសញ្ញារបស់សមាគមនៅ តាមខេត្ត ក្រុង ត្រូវយកលំនាំតាមសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដោយគ្រាន់តែប្តូរឈ្មោះ និងអក្សរកាត់ឱ្យស្របតាមឈ្មោះរបស់សមាគមនៅតាមខេត្ត ក្រុងនីមួយៗ។

### មាត្រា ២៩.-

គំរូលក្ខន្តិកៈរបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង មានចែងក្នុងឧបសម្ព័ន្ធនៃលក្ខន្តិកៈ របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់។

# ជំពូក ៥

# សមាជិកភាពរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់

## មាត្រា ៣០.-

សមាជិកភាពរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវបំពេញបានតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

- ជាសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង
- ដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងដោយមានសម្លេងយល់ព្រមមិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកទាំងអស់របស់ក្រុមប្រឹក្សាសមាគមខេត្ត ក្រុងសាមី
- បង់ប្រាក់សមាជិកភាពប្រចាំឆ្នាំ តាមការកំណត់របស់បទបញ្ជា
- អនុវត្តតាមលក្ខន្តិកៈ និងបទបញ្ជាសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

## មាត្រា ៣១.-

សមាជិកភាពរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ នឹងត្រូវបាត់បង់តាមករណីណាមួយដូចខាងក្រោម :

- ដាក់ពាក្យសុំលាលែងដោយស្ម័គ្រចិត្ត និងដោយមានសម្លេងយល់ព្រមមិនតិចជាងពីរភាគបីនៃចំនួន សមាជិកទាំងអស់របស់ក្រុមប្រឹក្សាសមាគមខេត្ត ក្រុងសាមី ។
- មិនបានបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំតាមការកំណត់ចំនួនពីរឆ្នាំបន្តបន្ទាប់ដោយគ្មានមូលហេតុ ។
- រំលោភលើលក្ខន្តិកៈ និងបទបញ្ជាសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។ ក្នុងករណីដែលសមាជិកតាមខេត្ត ក្រុង រំលោភលើបទប្បញ្ញត្តិនៃលក្ខន្តិកៈ ឬបទបញ្ជាសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ក្រុមប្រឹក្សាជាតិអាចព្យួរសមាជិកភាពរបស់សមាជិកតាមខេត្ត ក្រុងនោះ ។ ការព្យួរ

នេះ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិ ក្នុងសម្លេងគាំទ្រមិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាជាតិទាំងមូល ។

**មាត្រា ៣២.-**

ការចូលជាសមាជិកជាថ្មីរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវបំពេញតាមល័ក្ខខ័ណ្ឌមួយចំនួនដូចខាងក្រោម :

- ស្ម័គ្រចិត្តដាក់ពាក្យសុំចូលសមាជិកជាថ្មីម្តងទៀត
- ស្ម័គ្រចិត្តបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំដែលខ្លួនមិនបានបង់គ្រប់ចំនួនឡើងវិញ
- សន្យាជាលាយល័ក្ខណ៍អក្សរថានឹងកែលំអនូវកំហុសឆ្គងរបស់ខ្លួនកន្លងមក ។

## ជំពូក ៦
## ការងារហិរញ្ញវត្ថុ
## ប្រាក់ចំណូលរបស់សម្ព័ន្ធភាពជាតិ

**មាត្រា ៣៣.-**

មហាសន្និបាតអាចធ្វើប្រតិភូកម្មអំណាចឱ្យក្រុមប្រឹក្សាជាតិ កំណត់ និងពិនិត្យមើលឡើងវិញនូវចំនួនទឹកប្រាក់សមាជិកភាពប្រចាំឆ្នាំដែលសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងត្រូវប្រមូល ។

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ អាចទទួលប្រាក់ពីសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងនីមួយៗ តាមការចែករំលែកប្រាក់សមាជិកភាពប្រចាំឆ្នាំដែលសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងបានប្រមូល ។

**មាត្រា ៣៤.–**

ក្រៅពីប្រាក់សមាជិកភាពប្រចាំឆ្នាំ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ អាចទទួលចំណូលដែលបានមកពី :

- អតិរេក ឬប្រាក់សន្សំពីកម្មវិធី និងសកម្មភាពផ្សេងទៀតរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។
- វិភាជន៍ពីរាជរដ្ឋាភិបាល ។
- វិភាជន៍ វិភាគទាន និងអំណោយពីប្រភពស្របច្បាប់ផ្សេងទៀតរួមមានអ្នកផ្ដល់អំណោយ និងទីភ្នាក់ងារអន្តរជាតិ ។
- ប្រភពស្របច្បាប់ផ្សេងទៀតដែលមិនធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

**មាត្រា ៣៥.–**

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវផ្ដល់ និងផ្ទេរប្រាក់ចំណូល និងផលប្រយោជន៍ក្រៅពីប្រាក់សមាជិកភាពដែលទទួលបានពីសមាគមនៅតាមខេត្ត ក្រុងទៅឱ្យសមាគមនៅតាមខេត្ត ក្រុង ។ ការផ្ដល់ខាងលើនេះ ត្រូវកំណត់ដោយគណៈកម្មាធិការប្រតិបត្តិជាតិ ។

## ការធ្វើសវនកម្មរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងរបាយការណ៍សវនកម្ម

**មាត្រា ៣៦.–**

ជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាជាតិត្រូវតែងតាំងសវនករដើម្បីធ្វើសវនកម្ម ហើយរាយការណ៍ជូនសម្ព័ន្ធភាពជាតិ អំពីគណនីហិរញ្ញវត្ថុ ប្រព័ន្ធនៃការអនុវត្ត និង

សកម្មភាពទាំងអស់របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៅក្នុងឆ្នាំសារពើពន្ធ។

សវនករ ត្រូវតែជាសវនករដែលបានចុះបញ្ជីដោយឯករាជ្យ ហើយមានលក្ខណសម្បត្តិដែលត្រូវបានទទួលស្គាល់ជាលក្ខណៈជាតិ និងអន្តរជាតិនៅក្នុងការធ្វើសវនកម្ម។

បន្ទាប់ពីបានបញ្ចប់ការធ្វើសវនកម្ម សវនករត្រូវដាក់របាយការណ៍សវនកម្មជូនអង្គប្រជុំរបស់ក្រុមប្រឹក្សាជាតិភ្លាម ដើម្បីធ្វើការពិនិត្យ ពិភាក្សា និងអនុម័ត ។ ច្បាប់ចម្លងនៃរបាយការណ៍សវនកម្មត្រូវផ្តល់ជូនជាបន្ទាន់ដល់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ស្ថាប័ន និងទីភ្នាក់ងារទាំងអស់ដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់សម្ព័ន្ធភាពជាតិឃុំ សង្កាត់។

## ប្រាក់ឧបត្ថម្ភសម្ព័ន្ធភាពជាតិ

**មាត្រា ៣៧.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ អាចទទួលការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុក្នុងទឹកប្រាក់ដែលត្រូវបានគាំទ្រនៅក្នុងការប្រជុំជាចំហដោយប្រតិភូភាគច្រើនរបស់ក្រុមប្រឹក្សាជាតិ។

## ទ្រព្យសម្បត្តិរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ពេលរំសាយ

**មាត្រា ៣៨.-**

ប្រសិនបើសម្ព័ន្ធភាពជាតិឃុំ សង្កាត់ត្រូវបានប្រកាសរំសាយដោយស្ថាប័នមានសមត្ថកិច្ច ឬដោយមហាសន្និបាត ទ្រព្យសម្បត្តិទាំងអស់របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវផ្ទេរឱ្យមូលនិធិឃុំ សង្កាត់។

# ជំពូក ៧

# អន្តរប្បញ្ញត្តិ

## មាត្រា ៣៩.-

សមាជិកចូលរួមក្នុងមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់លើកទីមួយ គឺ ប្រតិភូចូលរួមមហាសន្និបាត ចំនួន២៥៨រូប សមាជិកក្រុមប្រឹក្សាជាតិ ចំនួន ១៩៨រូប ដែលបានសម្រេចក្នុងសន្និបាតក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសលើកទី២ នាថ្ងៃទី២២ - ២៤ ខែធ្នូ ឆ្នាំ២០០៤ គណៈកម្មាធិការប្រតិបត្តិជាតិ ចំនួន៥២រូប ដែលបានឯកភាព គ្នាក្នុងសម័យប្រជុំក្រុមការងារថ្នាក់ជាតិ នាថ្ងៃទី ០៨ - ០៩ ខែមេសា ឆ្នាំ២០០៥ ។

ប្រធាន អនុប្រធានសម្ព័ន្ធភាពជាតិ បានឯកភាពគ្នាក្នុងសម័យប្រជុំ ក្រុមការងារថ្នាក់ជាតិ នាថ្ងៃទី ០៨-០៩ ខែមេសា ឆ្នាំ២០០៦ គឺ មានប្រធានមួយ រូប និងអនុប្រធាន៣រូប ។

# ជំពូក ៨

# អវសានប្បញ្ញត្តិ

## មាត្រា ៤០.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១.-**

លក្ខន្តិកៈសម្ព័ន្ធភាពជាតិឃុំ សង្កាត់នៅកម្ពុជា មានសុពលភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៦

ព្រះរាជាណាចក្រកម្ពុជា
ប្រធាន
ស.ជ.ឃ.ស
សម្ព័ន្ធភាពជាតិឃុំ សង្កាត់

សយ-ភូសល

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុង

# សម្ព័ន្ធភាពជាតិឃុំ សង្កាត់
# នៃព្រះរាជាណាចក្រកម្ពុជា

# បទបញ្ជាផ្ទៃក្នុង
# សម្ព័ន្ធភាពជាតិឃុំ សង្កាត់

យោងលក្ខន្តិកៈសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដែលត្រូវបានមហាសន្និបាតលើកទី១របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ អនុម័តនាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៦ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ កំណត់បទបញ្ជាផ្ទៃក្នុងសម្រាប់អនុវត្ត ដូចខាងក្រោម ៖

## ១-អំពីការជ្រើសរើស
## អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន និងបុគ្គលិកបម្រើការងារ

**ប្រការ ១.-**

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ អាចជ្រើសរើសបុគ្គលិកចំនួន១រូបធ្វើជាអគ្គលេខាធិការរបស់ខ្លួន និងបុគ្គលិកមួយចំនួនថែមទៀតក្នុងករណីចាំបាច់ស្របតាមទំហំការងាររបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

**ប្រការ ២.-**

ការជ្រើសរើសបុគ្គលិកសម្រាប់ធ្វើជាអគ្គលេខាធិការ និងបុគ្គលិកបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវធ្វើជាចំហ និងផ្សព្វផ្សាយជាសាធារណៈ ។

**ប្រការ ៣.-**

បេក្ខជនដែលត្រូវបានជ្រើសរើស ត្រូវមានលក្ខណសម្បត្តិដូចបានកំណត់ក្នុងលក្ខន្តិកៈសម្ព័ន្ធភាពជាតិឃុំសង្កាត់ និងត្រូវឆ្លងកាត់ការសាកល្បងរយៈពេល ៣ខែ ។

**ប្រការ ៤.-**

បន្ទាប់ពីបានធ្វើការសាកល្បងរយៈពេល៣ខែរួចហើយ គណៈកម្មាធិការប្រតិបត្តិរបស់សម្ព័ន្ធភាពជាតិ ឃុំ សង្កាត់ត្រូវធ្វើការប្រជុំបូកសរុប និងវាយតម្លៃលើលទ្ធផលការងាររបស់បេក្ខជនដែលត្រូវសម្រេចជ្រើសរើស ។

**ប្រការ ៥.-**

ការសម្រេចជ្រើសតាំង ឬបញ្ឈប់បេក្ខជនធ្វើជាអគ្គលេខាធិការ និងបុគ្គលិកបម្រើការងារផ្សេងទៀត គឺអាស្រ័យដោយការសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ ។

**ប្រការ ៦.-**

អគ្គលេខាធិការសម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងបុគ្គលិកត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែស្របតាមទំហំការងារ និងភារកិច្ចដែលខ្លួនទទួលខុសត្រូវ ។ ការកំណត់ចំនួនប្រាក់ឧបត្ថម្ភ គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ ។

## ២-អំពីប្រាក់ភាគទានប្រចាំឆ្នាំ ប្រាក់វិភាគទាន និងប្រាក់បេសកកម្ម

**ប្រការ ៧.-**

សមាជិកទាំងអស់របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវបង់ប្រាក់ភាគទានប្រចាំឆ្នាំតាមការកំណត់របស់គណៈកម្មាធិការប្រតិបត្តិជាតិ ជូនសម្ព័ន្ធភាពជាតិឃុំ សង្កាត់ រៀងរាល់សប្តាហ៍ទី១ នៃខែធ្នូ ។

គណៈកម្មាធិការប្រតិបត្តិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្តក្រុងនីមួយៗ មានភារកិច្ចទទួលប្រមូល និងបូកសរុបប្រាក់ភាគទានរបស់

សមាជិកសមាគមនៅខេត្ត ក្រុងរបស់ខ្លួន ហើយផ្ញើបញ្ជី និងបញ្ជូនប្រាក់ ១៥ ភាគរយនៃប្រាក់ភាគទានសរុប ជូនអគ្គលេខាធិការដ្ឋានដោយផ្ទាល់ ឬតាមរយៈសាខាធនាគារដែលគណៈកម្មាធិការប្រតិបត្តិជាតិ បានកំណត់ ។

## ប្រការ ៨.-

ប្រាក់វិភាគទាន និងអំណោយរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើវិភាគទាន ឬអំណោយជាធនធានថវិកា សម្ភារ មធ្យោបាយដល់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ឬសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង អគ្គលេខាធិការ ឬលេខាធិការ មានភារកិច្ចទទួល និងកត់ត្រាចំនួនវិភាគទាន ឬអំណោយទាំងនោះឱ្យបានត្រឹមត្រូវ និងធ្វើប័ណ្ណថ្លែងអំណរគុណដោយដាក់ជូនប្រធានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ឬប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងចុះហត្ថលេខា ហើយផ្ញើប័ណ្ណថ្លែងអំណរគុណទៅម្ចាស់វិភាគទាន ឬអំណោយនោះ ។

## ប្រការ ៩.-

បេសកកម្មរបស់មន្ត្រីជាសមាជិកក្រុមប្រឹក្សា ឬជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ដែលត្រូវបានចាត់ឱ្យទៅបំពេញបេសកកម្មនៅកន្លែងណាដែលនាំឱ្យបាត់បង់សោហ៊ុយផ្ទាល់ខ្លួនសម្រាប់បេសកកម្ម សម្ព័ន្ធភាពជាតិឬសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចេញសោហ៊ុយសងវិញ ។ ប្រធានសម្ព័ន្ធភាពជាតិ ឬប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ នៅតាមខេត្ត ក្រុង ជាអ្នកសម្រេចផ្តល់សោហ៊ុយបេសកកម្មនេះ តាមសំណើរបស់អគ្គលេខាធិការ ឬលេខាធិការ ។

## ៣-អំពីការចារហិរញ្ញវត្ថុ

### ប្រការ ១០.-

រាល់ការចំណាយថវិការបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវមានការអនុញ្ញាតពីប្រធានសម្ព័ន្ធភាពជាតិ ។

រាល់ការចំណាយថវិការបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ត្រូវមានការអនុញ្ញាតពី ប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ។

### ប្រការ ១១.-

អគ្គលេខាធិការសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវរៀបចំបែបបទចំណាយថវិកាឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីហិរញ្ញវត្ថុ ដើម្បីបើកប្រាក់ជូនដល់អ្នកដែលមានសិទ្ធិចាយ បន្ទាប់ពីមានចំណារឯកភាពពីប្រធានសម្ព័ន្ធភាពជាតិ ។

លេខាធិការដ្ឋានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងត្រូវរៀបចំបែបបទចំណាយថវិកាឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីហិរញ្ញវត្ថុដើម្បីបើកប្រាក់ជូនដល់អ្នកដែលមានសិទ្ធិចាយ បន្ទាប់ពីមានចំណារឯកភាពពីប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ។

### ប្រការ ១២.-

ការទិញទំនិញត្រូវមានសមាសភាពអគ្គលេខាធិការ ឬលេខាធិការ និងអ្នកពាក់ព័ន្ធចូលរួម ។ រាល់ការទិញទំនិញត្រូវមានវិក្កយបត្រ ។ តម្លៃទំនិញត្រូវឱ្យស្របនឹងតារាងសម្រង់តម្លៃដែលបានសម្រេចរួចហើយ ។ ក្នុងករណីទំនិញនោះមានចំនួនតិចតួចដែលមិនអាចធ្វើវិក្កយបត្របាន ត្រូវរាយការណ៍ជូនប្រធានសម្ព័ន្ធភាពជាតិ ។ ចំពោះសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ក៏ អនុវត្តតាមនីតិវិធី

ដូចគ្នានេះដែរ ។

**ប្រការ ១៣.-**

អ្នកទិញទំនិញ ត្រូវធ្វើការស្រង់តម្លៃពីកន្លែងលក់ទំនិញយ៉ាងតិចពីរកន្លែង ដើម្បីពិនិត្យពិចារណាពីតម្លៃ និងគុណភាព ។

**ប្រការ ១៤.-**

អគ្គលេខាធិការសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ឬលេខាធិការសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ត្រូវធ្វើបញ្ជីស្រង់ និងតាមដានតម្លៃទំនិញប្រចាំឆមាសឱ្យបានត្រឹមត្រូវ និងមានតម្លាភាព ។

**ប្រការ ១៥.-**

ការចុះបញ្ជី និងការទូទាត់លើការងារចំណូល ចំណាយថវិកា ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ ដោយមានកត់ត្រាចេញ ចូល ក្នុងសៀវភៅសាច់ប្រាក់ និងមានប័ណ្ណចំណូលឬប័ណ្ណចំណាយ ដើម្បីងាយស្រួលតាមដានរាល់ចលនាសាច់ប្រាក់ ។

**ប្រការ ១៦.-**

សៀវភៅសាច់ប្រាក់ត្រូវចុះបញ្ជីឱ្យបានច្បាស់លាស់អំពី កាលបរិច្ឆេទ បរិយាយលេខកូដប័ណ្ណ បរិមាណចំណាយ ដែលអាចឆ្លុះបញ្ចាំងលើសកម្មភាពនៃការផ្ញើប្រាក់ ការដកប្រាក់ពីធនាគារ ការទទួលចំណូល ការចំណាយ ការប្តូរប្រាក់ការធ្វើបុរេប្រទាន ការសងបុរេប្រទាន និងការខ្ចីពីខាងក្រៅ ។

**ប្រការ ១៧.-**

ប័ណ្ណចំណូល ត្រូវកត់ត្រារាល់ចលនាប្រាក់ចូលទាំងអស់ ដូចជា :

- ប្រាក់ភាគទាន

- ប្រាក់វិភាគទាន និងអំណោយ
- ប្រាក់បានមកពីសេវាកម្មផ្សេងៗ
- ការសងបុរេប្រទាន និងការខ្ចីពីខាងក្រៅ
- ការដកប្រាក់ពីគណនីធនាគារ ទុកក្នុងបេឡា ឬផ្ទេរទៅឱ្យសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង
- ប្រភពសាច់ប្រាក់ចំណូលស្របច្បាប់ផ្សេងៗទៀត។

អនុវត្តនីតិវិធីដូចគ្នានេះ ចំពោះសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ នៅតាមខេត្ត ក្រុង។

**ប្រការ ១៨.-**

បណ្ណចំណាយ ត្រូវកត់ត្រារាល់ចលនាប្រាក់ចេញទាំងអស់ ដូចជា :

- ប្រាក់ឧបត្ថម្ភ
- ការចំណាយទូទៅ
- ការធ្វើបុរេប្រទាន។

**ប្រការ ១៩.-**

បណ្ណចំណូល បណ្ណចំណាយ និងឯកសារពាក់ព័ន្ធ ត្រូវត្រួតពិនិត្យ និងចុះហត្ថលេខាដោយប្រធានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ រៀងរាល់សប្តាហ៍ ។ អនុវត្តនីតិវិធីដូចគ្នានេះ ចំពោះសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

**ប្រការ ២០.-**

អគ្គលេខាធិការសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវធ្វើរបាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ តារាងតុល្យការ និងបញ្ជីចំណូលចំណាយ ដោយមានវិក្កយបត្រឬឯកសារសំអាងជូនប្រធានសម្ព័ន្ធភាពជាតិ ពិនិត្យ និងសម្រេចនៅ

រៀងរាល់សប្តាហ៍ទី១នៃខែបន្ទាប់។ របាយការណ៍នេះត្រូវធ្វើប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។ ដោយឡែករបាយការណ៍អំពីបញ្ជីសារពើភ័ណ្ឌ ត្រូវធ្វើប្រចាំឆមាស និងប្រចាំឆ្នាំ។ អនុវត្តនីតិវិធីដូចគ្នានេះ ចំពោះសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

## ៤-អំពីប្រតិបត្តិការធនាគារ

### ប្រការ ២១.-

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវបើកគណនីនៅធនាគារណាមួយនៅក្នុងប្រទេសកម្ពុជា ហើយដែលធនាគារនោះ មានសាខារបស់ខ្លួននៅតាមបណ្តាខេត្ត ក្រុង និងមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។ ការបើកគណនីក្នុងនាមសម្ព័ន្ធភាពជាតិឃុំ សង្កាត់នៅធនាគារ ត្រូវចុះហត្ថលេខាចំនួនបីរូប គឺ ប្រធាន និងអនុប្រធាន។ ប្រធានសម្ព័ន្ធ ភាពជាតិ គឺជាម្ចាស់គណនី។ ថវិកាទាំងអស់ត្រូវរក្សាទុកនៅក្នុងគណនីធនាគារក្នុងនាមសម្ព័ន្ធភាពជាតិឃុំ សង្កាត់ លើកលែងតែថវិកាចំនួន ១.០០០.០០០រៀល (មួយលានរៀល) ដែលត្រូវទុកក្នុងបេឡាសម្រាប់បម្រើការងារ ចំណាយបន្ទាន់ និងចាំបាច់។

សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ត្រូវបើកគណនីរបស់ខ្លួននៅធនាគារដែលជាសាខាធនាគារដែលសម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានបើកគណនី។

### ប្រការ ២២.-

ការដាក់ប្រាក់ក្នុងធនាគារ ឬការដក ឬផ្ទេរប្រាក់ពីធនាគារ ត្រូវមានចុះហត្ថលេខារបស់ប្រធានសម្ព័ន្ធភាព ជាតិឃុំ សង្កាត់ ។ អនុវត្តនីតិវិធីដូចគ្នានេះ ចំពោះសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

## ៥-ការធ្វើសវនកម្មហិរញ្ញវត្ថុ

### ប្រការ ២៣.-

រាល់សកម្មភាពគណនីហិរញ្ញវត្ថុ និងប្រព័ន្ធអនុវត្តសកម្មភាពទាំងអស់របស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ត្រូវធ្វើសវនកម្មរៀងរាល់ឆ្នាំ។ ក្រុមប្រឹក្សាជាតិ ត្រូវតែងតាំងសវនករដែលបានចុះបញ្ជីដោយឯករាជ្យ និងទទួលស្គាល់ដោយអាជ្ញាធរសវនកម្មជាតិ ឬអន្តរជាតិ ក្នុងការងារសវនកម្ម។

### ប្រការ ២៤.-

រៀងរាល់ដំណាច់ឆ្នាំ សវនកររបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ត្រូវធ្វើសវនកម្មលើគណនីរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដើម្បីដាក់ជូនអង្គប្រជុំក្រុមប្រឹក្សាជាតិ ពិនិត្យ ពិភាក្សា និងសម្រេច។

សវនកររបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ត្រូវធ្វើសវនកម្មលើគណនីរបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ដើម្បីដាក់ជូនអង្គប្រជុំក្រុមប្រឹក្សាសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាម ខេត្ត ក្រុង ពិនិត្យ ពិភាក្សា និងសម្រេច។

### ប្រការ ២៥.-

គ្រប់របាយការណ៍សវនកម្ម ត្រូវដាក់ជូនមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងសន្និបាតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ពិនិត្យ អនុម័ត។ ច្បាប់ចម្លងនៃរបាយការណ៍សវនកម្ម ត្រូវផ្តល់ជូន សមាជិកសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ស្ថាប័ន និងទីភ្នាក់ងារដែលមានការគាំទ្រផ្នែកហិរញ្ញវត្ថុ

ដល់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

## ៦_អំពីការប្រជុំ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គណៈកម្មាធិការប្រតិបត្តិជាតិ ឬសន្និបាតសមាគម និងប្រតិភូចូលរួមក្នុងមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់

### ប្រការ ២៦._

រាល់ការប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការប្រតិបត្តិជាតិ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាម ខេត្ត ក្រុង ត្រូវមានកូរ៉ុមចូលរួមប្រជុំលើសពីពាក់កណ្តាលនៃសមាជិកទាំងមូលរបស់ក្រុមប្រឹក្សា គណៈកម្មាធិការប្រតិបត្តិរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

ការសម្រេចរបស់ក្រុមប្រឹក្សា គណៈកម្មាធិការប្រតិបត្តិជាតិ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាម ខេត្ត ក្រុង អាចយកជាការបានលុះត្រាតែការអនុម័តនោះមានសម្លេងគាំទ្រយ៉ាងតិច ៥០%+១ នៃចំនួនសមាជិកទាំងមូលរបស់ក្រុមប្រឹក្សា គណៈកម្មាធិការប្រតិបត្តិជាតិ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង។

### ប្រការ ២៧._

ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលអាចបញ្ជូនសមាជិករបស់ខ្លួនឈរឈ្មោះ

ជាបេក្ខជនក្រុមប្រឹក្សាសមាគម ឬគណៈកម្មាធិការប្រតិបត្តិសមាគមនៅតាមខេត្ត ក្រុងបាន លុះត្រាតែក្រុមប្រឹក្សាឃុំ សង្កាត់នោះ បានចូលជាសមាជិករបស់សមាគម ក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ជាផ្លូវការ ។

**ប្រការ ២៨.-**

សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ដែលអាចបញ្ជូនប្រតិភូរបស់ខ្លួនឈរឈ្មោះជាបេក្ខជន ក្រុមប្រឹក្សាជាតិបាន លុះត្រាតែសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុងនោះ បានចូលជាសមាជិករបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ជាផ្លូវការ ។

**ប្រការ ២៩.-**

ការបោះឆ្នោតជ្រើសរើសប្រតិភូចូលរួមក្នុងមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ត្រូវជ្រើសរើសឡើង ដោយសន្និបាតសមាគមនៅតាមខេត្ត ក្រុងក្នុងចំណោមសមាជិកក្នុងក្រុមប្រឹក្សាសមាគមនៅតាមខេត្ត ក្រុងរបស់ខ្លួន។ នីតិវិធីបោះឆ្នោតជ្រើសរើសប្រតិភូ ត្រូវធ្វើឡើងដោយសម្ងាត់ក្នុងសន្និបាតសមាគមនៅតាមខេត្ត ក្រុង និងឆ្លងតាមការអនុម័តមតិភាគច្រើនដាច់ខាត ៥០%+១ នៃសមាជិកពេញសិទ្ធិចូលរួមក្នុងមហាសន្និបាតសម្ព័ន្ធភាពជាតិ ឃុំ សង្កាត់ ។
គណៈកម្មាធិការប្រតិបត្តិជាតិ ជាអ្នកកំណត់សមាសភាព និងចំនួនប្រតិភូដែលត្រូវចូលរួមក្នុងមហាសន្និបាត ។

**ប្រការ ៣០.-**

ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឬគណៈកម្មាធិការប្រតិបត្តិប្រធាន ឬអនុប្រធាន ត្រូវធ្វើឡើងដោយសម្ងាត់ និងមានសម្លេងគាំទ្រភាគច្រើន

ដាច់ខាត ៥០%+១ នៃសមាជិកពេញសិទ្ធិចូលរួមមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ។

**ប្រការ ៣១.-**

ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិឃុំ សង្កាត់ ឬរបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅ តាមខេត្ត ក្រុង ត្រូវអនុវត្តទៅតាមមុខងារ តួនាទី ភារកិច្ច និងរបៀបរបបប្រជុំការងារដូចបានកំណត់ក្នុងលក្ខន្តិកៈរបស់ខ្លួន ។

**ប្រការ ៣២.-**

ប្រធានក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិឃុំ សង្កាត់ ឬសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅ តាមខេត្ត ក្រុង ត្រូវបើកការប្រជុំពិសេសរបស់ខ្លួនបន្ទាប់ពីបានជាប់ឆ្នោតជាក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិដើម្បីធ្វើការបែងចែកតួនាទី ភារកិច្ចដល់សមាជិកក្នុងក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ ។

**ប្រការ ៣៣.-**

គ្រប់ការបោះឆ្នោត ត្រូវរៀបចំឱ្យមានគណៈកម្មការបោះឆ្នោត ។ សមាសភាពគណៈកម្មការបោះឆ្នោត ត្រូវសុំការអនុម័តពីមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ឬសន្និបាតសមាគម ។

**ប្រការ ៣៤.-**

ក្នុងដំណើរការបោះឆ្នោតនីមួយៗ ប្រធានគណៈកម្មការបោះឆ្នោត ត្រូវបែងចែកភារកិច្ចដល់សមាជិកក្នុងគណៈកម្មការបោះឆ្នោត ឱ្យទទួលការងារ : បង្ហាញហិបឆ្នោត ចែកសន្លឹកឆ្នោត ពិនិត្យនិងរាប់សន្លឹកឆ្នោតដែលបានបោះរួច

កត់ត្រាសន្លឹកឆ្នោតគាំទ្រ មិនគាំទ្រ អនុប្បវាទ និងសន្លឹកឆ្នោតមិនបានការរបស់បេក្ខជនឈរឈ្មោះនីមួយៗ និងធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការបោះឆ្នោត ។ ប្រធានគណៈកម្មការបោះឆ្នោត ត្រូវអានឈ្មោះបេក្ខជនឈរឈ្មោះ បង្ហាញនិងណែនាំពីលក្ខណៈនៃសន្លឹកឆ្នោត និងរបៀបគូសសន្លឹកឆ្នោតដែលចាត់ទុកជាបានការ និងមិនបានការ ។

**ប្រការ ៣៥.-**

នៅពេលមានសមាជិកក្នុងក្រុមប្រឹក្សា ឬគណៈកម្មាធិការប្រតិបត្តិណាម្នាក់ បានបាត់បង់សមាជិកភាព របស់ខ្លួនពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាជាតិ ឬក្រុមប្រឹក្សាសមាគមនៅតាមខេត្ត ក្រុង ត្រូវបើកអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងសម្របសម្រួលជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់មកជំនួសវិញ ។

**ប្រការ ៣៦.-**

ក្នុងករណីមានការបាត់បង់ប្រធានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ឬប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅ តាមខេត្ត ក្រុង ក្រុមប្រឹក្សាជាតិ ឬក្រុមប្រឹក្សាសមាគមនៅតាមខេត្ត ក្រុង ត្រូវបើកអង្គប្រជុំពិសេស ដើម្បីធ្វើការពិនិត្យពិភាក្សា និងសម្រេចជ្រើសរើសអនុប្រធាន ឬអនុប្រធានណាម្នាក់ (បើមានអនុប្រធាន ២រូប) ឱ្យទទួលជា ប្រធានស្តីទីរហូតដល់មានការបោះឆ្នោតជ្រើសតាំងប្រធានពេញសិទ្ធិជាថ្មីឡើងវិញ ។

## ៧-អំពីក្រុមការងារ

**ប្រការ ៣៧.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ បានសម្រេចបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីជួយរៀបចំសេចក្តីព្រាងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ប្រមូលមតិ

យោបល់ កែសម្រួល ឬបំពេញបន្ថែមលើសេចក្តីព្រាងលក្ខន្តិកៈ និងសម្របសម្រួលក្នុងដំណើរការរៀបចំសន្និបាតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង និងមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់លើកទី ១។

## ប្រការ ៣៨.~

ក្រុមការងារនេះ ត្រូវប្រកាសរំសាយភ្លាមបន្ទាប់ពីបានរៀបចំបង្កើតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅ តាមខេត្ត ក្រុង គ្រប់ខេត្ត ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា បញ្ចប់ជាស្ថាពរ។

# ៨~អន្តរប្បញ្ញត្តិ

## ប្រការ ៣៩.~

ក្នុងមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់លើកទី១នេះ ប្រតិភូពេញសិទ្ធិចូលរួមមហាសន្និបាតត្រូវកំណត់យកចំនួនមិនលើសពី៣២៤រូប ស្មើនឹង២០% នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស។ ក្រុមប្រឹក្សាជាតិ មានសមាជិកចំនួនមិនលើសពី១៩៨រូប ដែលបានសម្រេចក្នុងសន្និបាតក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសលើកទី២ នាថ្ងៃទី ២២-២៤ ខែធ្នូ ឆ្នាំ២០០៤ ។ គណៈកម្មាធិការប្រតិបត្តិជាតិ មានសមាជិកចំនួនមិនលើសពី៥២រូប ដែលបានឯកភាពគ្នាក្នុងសម័យប្រជុំក្រុមការងារថ្នាក់ជាតិ នាថ្ងៃទី ០៨-០៩ ខែ មេសា ឆ្នាំ២០០៥។

សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មានប្រធានមួយរូប និងអនុប្រធាន ៣រូប

ដែលបានឯកភាពក្នុងសម័យប្រជុំក្រុមការងារថ្នាក់ជាតិនាថ្ងៃទី ០៨-០៩ ខែមេសា ឆ្នាំ២០០៥។

ក្រុមការងារថ្នាក់ជាតិ ជាអ្នកកំណត់ចំនួនប្រតិភូសង្កេតការណ៍របស់ខេត្ត ក្រុងដែលមិនទាន់បានបង្កើត សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត ក្រុង ដើម្បីចូលរួមមហាសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់លើកទី១នេះ ។

## ប្រការ ៤០.-

គណៈកម្មាធិការប្រតិបត្តិជាតិឃុំ សង្កាត់ មានភារកិច្ចធ្វើការណែនាំ អនុវត្តបទបញ្ជាផ្ទៃក្នុងឱ្យបានស្រប តាមសភាពការណ៍ជាក់ស្តែងក្នុងដំណាក់កាលនីមួយៗ ។

## ប្រការ ៤១.-

ក្រុមការងារថ្នាក់ជាតិបង្កើតសម្ព័ន្ធភាពជាតិឃុំ សង្កាត់ អាចបង្កើត លេខាធិការដ្ឋាន ដើម្បីសម្រួលដល់ការងាររបស់ខ្លួន ។ លេខាធិការដ្ឋាននេះ នឹងក្លាយជាអគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៅពេលសម្ព័ន្ធភាព ជាតិឃុំ សង្កាត់ បានចុះបញ្ជីតម្កល់សំណុំលិខិតជាផ្លូវការនៅក្រសួងមហាផ្ទៃ ។

## ប្រការ ៤២.-

បទបញ្ជាផ្ទៃក្នុងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦

**ប្រធានសម្ព័ន្ធភាពជាតិឃុំ សង្កាត់**

**សយ_ភូសល**